**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៦២៩....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការទីស្នាក់ការគយ និងរដ្ឋាករ ប្រចាំសន្និធិគយបណ្តោះអាសន្ន សូ ខួន បាទិត
## (ទីស្នាក់ការគយ និងរដ្ឋាករ ផែស្ងួត សូ ខួន បាទិត)

*** ***

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញសេចក្តីជូនដំណឹងលេខ ៧៣២ សជណ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ៩២០ សហវ.ប្រក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយ និងរដ្ឋាករ
- បានឃើញប្រកាសលេខ ១០៦ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសន្និធិគយបណ្តោះអាសន្ន

- យោងកិច្ចសន្យាស្តីពីការបង្កើត និងធ្វើអាជីវកម្មសន្និធិគយបណ្តោះអាសន្ន (ផែស្ងួត) បាវិត សំរាប់បញ្ចេញទំនិញពីគយ និងរដ្ឋាករ រវាងទីចាត់ការគយ និងរដ្ឋាករ និងក្រុមហ៊ុន ស៊ូ ង៉ួន ដឹកជញ្ជូន និងសេវា អាហរណ៍ នីហរណ៍ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៨
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** បង្កើត និងដាក់ឱ្យដំណើរការនូវទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត ស៊ូ ង៉ួន បាវិត ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់សាខាគយ និងរដ្ឋាករខេត្តស្វាយរៀង នៃទីចាត់ការគយ និងរដ្ឋាករ ។

**ប្រការ ២:** ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត ស៊ូ ង៉ួន បាវិត ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣:** ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួត ស៊ូ ង៉ួន បាវិត មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង និងត្រួតពិនិត្យទំនិញ និងមធ្យោបាយដឹកជញ្ជូនក្នុងទីតាំងសន្និធិគយបណ្តោះអាសន្ន ស៊ូ ង៉ួន បាវិត លើគ្រប់មុខទំនិញ និងមធ្យោបាយដឹកជញ្ជូននាំចេញ-នាំចូលតាមប្រព័ន្ធកុងតឺន័រ និងតាមមធ្យោបាយដឹកជញ្ជូននាំចេញ-នាំចូលទាំងអស់ តាមមាត់ច្រកបាវិត លើកលែងតែ :
  - សំភារៈផ្ទាល់ខ្លួនរបស់អ្នកដំណើរ អ្នកបើកបរ និងសំរាប់តម្រូវការរបស់មធ្យោបាយដឹកជញ្ជូន
  - ការនាំចេញ-នាំចូលគ្មានលក្ខណៈពាណិជ្ជកម្ម និងការនាំចេញ-នាំចូលម្តងម្កាលរបស់ប្រជាជន ដែលរស់នៅតំបន់ព្រំដែន
  - ទំនិញនាំចេញដែលបានបំពេញបែបបទគយរួច នៅការិយាល័យគយ និងរដ្ឋាករនាំចេញ ក្រោមរូបភាពការិយាល័យសហព័ន្ធ ជាមួយមន្ត្រីកាំកុងត្រួលរួចហើយ និងមានកិបត្រាគយសំគាល់ត្រឹមត្រូវ
  - ទំនិញដឹកជញ្ជូនឆ្លងកាត់ជាអន្តរជាតិ
  - ទំនិញនាំចេញ-នាំចូលរបស់តំបន់សេដ្ឋកិច្ចពិសេស
  - ទំនិញនាំចូល ដែលស្ថិតក្រោមរបបឆ្លងកាត់ជាតិ មកបំពេញបែបបទគយនៅតាមសន្និធិគយបណ្តោះអាសន្ននានានៅផ្ទៃក្នុងប្រទេស
  - ទំនិញនាំចេញ-នាំចូលផ្សេងទៀត តាមការកំណត់ ឬសំរេចដាយថាហេតុពីនាយកទីចាត់ការគយ និងរដ្ឋាករ តាមសំណូមពរជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ឬរបស់បុគ្គលពាក់ព័ន្ធផ្សេងទៀត។

- ចាត់តាំងក្រុមអនុរក្ស និងក្រុមត្រួតពិនិត្យលើកិច្ចប្រតិបត្តិការគ្រប់គ្រងទំនិញនាំចេញ នាំចូល ដែលស្ថិតនៅក្នុងសន្និធិគយបណ្តោះអាសន្ន ស្វ ងួន បារិត លើទំនិញដូចចែងខាងលើ។
- ត្រួតពិនិត្យ និងប្រមូលពន្ធចំពោះមុខទំនិញនាំចូល នាំចេញដូចចែងខាងលើ និងអនុញ្ញាតឱ្យទំនិញចេញពីសន្និធិគយបណ្តោះអាសន្ន ក្រោយពីការត្រួតពិនិត្យ និងបញ្ចប់បែបបទគយតាមបទបញ្ញត្តិច្បាប់ជាធរមាន។

<u>**ប្រការ ៤:**</u> ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

<u>**ប្រការ ៥:**</u> ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

គាត ឈន់

<u>**ចម្លងជូន :**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- សាលាខេត្តស្វាយរៀង
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ